# ការស៊ើបអង្កេតរបស់ព្រឹទ្ធសភា អំពីការបោកគ្រាប់បែក
# SENATE INVESTIGATION ON GRENADE ATTACK

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩
សូមគោរពមកលោកព្រឹទ្ធសភា ចេស្ស៊ី-ហែមស៍ (Jesse Helms)
ប្រធានគណកម្មការ ទំនាក់ទំនងការបរទេស
សូមគោរពមកលោកព្រឹទ្ធសភា ចូស្សិប-បៃដឹន (Joseph Biden)
គណកម្មការ ទំនាក់ទំនងការបរទេស

លោកព្រឹទ្ធសភា ហែមស៍ និងលោកព្រឹទ្ធសភា បៃដឹន (Biden) :

ផ្ជាប់មកជាមួយនេះគឺជារបាយការណ៍ អំពីដំណើរទាំងពីរលើករបស់ខ្ញុំ ទៅកាន់ប្រទេសកម្ពុជា នៅពេលថ្មីៗកន្លងមកនេះ គឺនៅខែធ្នូ ១៩៩៨ និងខែមិថុនា ១៩៩៩ ។ គោលដៅទីមួយនៃដំណើរបេស់ខ្ញុំនេះ គឺការបោកគ្រាប់បែក ថ្ងៃទី៣០ ខែមិនា ១៩៩៧ នៅប្រទេសកម្ពុជា ដែលមានជនជាតីអាមេរិកាំងម្នាក់បានត្រូវរបួស ហើយបានត្រូវក្រសួងស៊ើបអង្កេតសហព័ន្ធ (FBI) ស៊ើបអង្កេត ។ នៅក្នុងដំណើរ ខែធ្នូ ១៩៩៨ ខ្ញុំបានទៅជាមួយលោក ផល បែរកូវិធ (Paul Berkowitz) ហើយនិងលោក ចូសិប-រីស៍ (Joseph Rees) មកពីគណកម្មការទំនាក់ទមនងអន្តរជាតិនៃរដ្ឋសភា ។
នៅក្នុងដំណើរ ខែកក្កដា ១៩៩៩ ខ្ញុំបានទៅជាមួយលោក ផល-បែរកូវិធ ហើយនិងលោក ម៉ៃកូល-វេសហៃ (Michael Westphai) មកពីគណកម្មការទំនាក់ទំនងអន្តរជាតិនៃព្រឹទ្ធសភា ។
មកទល់នឹងពេលនេះ ឧក្រិដ្ឋជនបោកគ្រាប់បែក មិនទាន់បានត្រូវរកឃើញមុខនៅឡើយទេ ។ ក៏ប៉ុន្តែដោយយោលទៅតាមការវិនិច្ឆ័យរបស់ខ្ញុំ និងយោលទៅតាមភស្តុតាងដែលមានក្នុងនោះ មានទាំងរបាយការណ៍របស់ក្រសួងស៊ើបអង្កេតសហព័ន្ធ (FBI) សារពត៌មាន ហើយនិងសេចក្តីសម្ភាសន៍ជាច្រើន នៅកម្ពុជា នៅថៃ និងនៅសហរដ្ឋអាមេរិក ។

របាយការណ៍របស់ខ្ញុំ តម្រូវឲ្យខ្ញុំសនិដ្ឋានដូចតទៅនេះ :

១) កងកម្លាំងអង្គរក្សហ៊ុន-សែន បានចូលរួមរៀបចំផែនការ និងអនុវត្តការគប់គ្រាប់បែក នៅថ្ងៃទី៣០ ខែមិនា ១៩៩៧នេះ ។
២) ហ៊ុន-សែន គឺជាមនុស្សតែមួយគត់ ក្នុងចំណោមមនុស្សពីរនាក់ ដែលមានអំណាច និងឥទ្ធិពលលើកងកម្លាំងអង្គរក្ស ហើយដែលបានដឹង បានឮ និងអនុញ្ញាតឲ្យបោកគ្រាប់បែកនោះ ។
៣) នៅក្នុងខែមិថុនា ១៩៩៧ រដ្ឋាភិបាលសហរដ្ឋអាមេរិក មានភស្តុតាងយ៉ាងសន្ធឹកសន្ធាប់អំពីសេចក្តី

សន្និដ្ឋានទី១ និងទី២ ខាងលើនេះហើយ ឥតមានបានធ្វើអ្វីទាំងអស់អំពីរឿងនេះ ។

ដោយសារតែភាពព្រងើយកន្តើយក្នុងរឿងនេះហើយ បានជាផលវិបាកអវិជ្ជមាន បានធ្លាក់មកលើលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ សព្វថ្ងៃនេះ ហ៊ុន-សែន នៅតែកាន់អំណាចតែម្នាក់ឯងដដែល ក្នុងកម្ពុជាដីកំសត់នេះ ។ ដោយសារតែភាពសោះអង្គើយ របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក មកលើប្រទេសកម្ពុជានេះហើយ បានជា ហ៊ុន-សែន បានរំលំដោយជោគជ័យ នូវលទ្ធផលបោះឆ្នោតឆ្នាំ១៩៩៣ របស់អង្គការសហប្រជាជាតិ ហើយដែលអន្តរជាតិក៏បានទទួលស្គាល់ថែមទៀតផង ។ ផ្នែកមួយនៃភាពសោះអង្គើយនោះ គឺរដ្ឋាភិបាលសហរដ្ឋអាមេរិក មិនចង់ប្រឈមមុខជាមួយ ហ៊ុន-សែន នៅក្នុងរឿងសម្លាប់រង្គាលបង្ហូរឈាមនេះ បើទោះណាជាមានភស្តុតាងយ៉ាងនេះក៏ដោយ ។ របាយការណ៍បានលាតត្រដាងការពិត ដែលធ្វើឲ្យខ្ញុំសន្និដ្ឋានដូច្នេះ ។

ដោយក្តីស្មោះពីខ្ញុំ
ជេម-ដូរ៉ាន់ (James Doran)
បុគ្គលិកជំនាញ ខាងកិច្ចអាស៊ីបូព៌ា

## បញ្ជីរាយនាម ដែលមាននៅក្នុងរបាយការណ៍

? ហ៊ុន-សែន អតីតទាហានខ្មែរក្រហម ចូលរួមក្នុងរដ្ឋាភិបាលបន្តុបដោយយួន ពីឆ្នាំ១៩៧៩ ហើយកាន់អំណាចចាប់ពីឆ្នាំ១៩៨៥មក ។

? ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ អ្នកឈ្នះសន្លឹកឆ្នោត ឆ្នាំ១៩៩៣ - សហនាយករដ្ឋមន្ត្រីទី១ ជាមួយ ហ៊ុន-សែន ឆ្នាំ១៩៩៣-១៩៩៧ ។

? សម-រង្ស៊ី អ្នកនយោបាយជំទាស់, ជាគោលដៅនៃការបោកគ្រាប់បែក ។

? រ៉ុន-អាប់នី (Ron Abney) ជនជាតិអាមេរិកាំង បានត្រូវរបួសក្នុងពេលបោកគ្រាប់បែក ។

? ឧត្តមសេនីយ៍ ហ៊ុយ-ពិសិដ្ឋ - មេបញ្ជាការកងពលអង្គរក្សហ៊ុន-សែន ។

? ហ៊ឹម-ប៊ុនហ៊ាង - អ្នកជំនួយ(ភ្ជួឈ្មួយ) ឧត្តមសេនីយ៍ ហ៊ុយ-ពិសិដ្ឋ ។

? ឈិន-សារ៉ុន - មេបញ្ជាការកងកម្លាំងអង្គរក្ស ប្រចាំទីលានបោកគ្រាប់បែក ថ្ងៃ៣០ ខែមិនា ។

? ម៉ុក-ជីតូ - មេបញ្ជាការប៉ូលិសក្រុងភ្នំពេញ ជាក្មួយ ហ៊ុន-សែន ។

? ស-ខេង - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មកពីគណបក្សប្រជាជនរបស់ ហ៊ុន-សែន ។

? ឧត្តមសេនីយ៍ តេង-សារ៉ុន - មេបញ្ជាការស៊ើបអង្កេត ក្នុងរឿងបោកគ្រាប់បែកនេះ ។

? ប្រេស៊ីល (Brazil) - ឈ្មោះប្រឌិត ជាជនសង្ស័យយ៉ាងសំខាន់ក្នុងរឿងនេះ ។

? ឧត្តមសេនីយ៍ ញឹក-ប៊ុនឆៃ - អតីតមេបញ្ជាការជាន់ខ្ពស់នៃកងទ័ព ដែលបានចាប់ឃុំឃាំងជនឈ្មោះ ប្រេ-ស៊ីល (Brazil) មួយរយៈ ។

? ឆាយ-វី ខ្មែរម្នាក់ដែលបានសារភាព ថាបានចូលរួមក្នុងរឿងឧក្រិដកម្ម ហើយដែលក្រោយមក ក៏និយាយបដិសេធវិញ ។

? ជុំ-ប៊ុនធឿន - ជាអ្នករួមគំនិតជាមួយ ឆាយ-វី ។

? គុន-គីម - ភ្ជួឈ្មួយអភិបាលខេត្តកណ្តាល ជាអ្នកជិតស្និទ្ធនឹង ហ៊ុន-សែន ។

## I - សេចក្តីផ្តើម

នៅថ្ងៃទី៣០ ខែមិនា ១៩៩៧ ប្រទេសកម្ពុជាបានទទួល ការវាយប្រហាបង្ហូរឈាម ដោយការបោកគ្រាប់បែកទៅលើបាតុកម្មប្រជុំមហាជនមួយ រៀបចំឡើងដោយគណបក្សប្រឆាំង របស់លោក សម-រង្ស៊ី ។ បន្ទាប់ពីកិច្ចប្រជុំបានផ្តើមឡើង ប្រហែលជាម៉ោង៨:៣០ព្រឹក ជនមិនស្គាល់មុខ បានគប់គ្រវែងគ្រាប់បែកដៃ ចំនួន៤គ្រាប់ទៅលើហ្វូងមនុស្ស (អង្គប្រជុំ) ដែលធ្វើឲ្យស្លាប់យ៉ាងហោចណាស់១៦នាក់ ហើយត្រូវរបួសជាង១៥០នាក់ ។ លោក សម-រង្ស៊ី ប្រហែលជាគោលដៅនៃអំពើពិឃាដនេះ ឥតបានត្រូវរបួសអ្វីឡើយ ក៏ប៉ុន្តែអង្គរក្សផ្ទាល់របស់លោកម្នាក់បានស្លាប់ក្នុងឧក្រិដ្ឋកម្មនោះ ។ ជនជាតិអាមេរិកាំងឈ្មោះ រ៉ន-អាប់នីយ៏ (Ron Abney) សមាជិករបស់អង្គារអន្តរជាតិ បក្សសាធារណរដ្ឋ ដែលបានដើរតាមលោក សម-រង្ស៊ី បានត្រូវរបួសជើងនិងចង្កេះរបស់គាត់ ។

វាំពេចនោះលោក សម-រង្ស៊ី ក៏បានថ្កោលទោស ហ៊ុន-សែន ថាជាអ្នកនៅពីក្រោយឧក្រិដ្ឋកម្មនេះ ។ ជាដំបូង ហ៊ុន-សែន បានចោទប្រកាន់ខ្មែរក្រហម ប៉ុន្តែក្រោយមកបែរជាចោទប្រកាន់ថាលោក សម-រង្ស៊ី បានបោកគ្រាប់បែកមកលើខ្លួនឯងវិញ ។ បន្ទាប់មកទៀត រដ្ឋាភិបាលខ្មែរក៏បានបង្កើតគណកម្មការមួយឡើង ដើម្បីស៊ើបអង្កេតពីឧប្បត្តិហេតុនេះ ។

មកទល់ពេលនេះ មិនទាន់រកឃើញឧក្រិដ្ឋជនទាំងនោះនៅឡើយ ។ គេរកមុខអ្នកបោកគ្រាប់បែកពិតប្រាកដនោះ មិនទាន់ឃើញនៅឡើយទេ រីឯមេគំនិតឧក្រិដ្ឋកម្មនោះ ក៏មិនទាន់រកឃើញនៅឡើយដែរ ។ ក៏ប៉ុន្តែនេះជាគំនិតរបស់ខ្ញុំ ដែលខ្ញុំមានភស្តុតាងគ្រប់គ្រាន់ ល្មមឲ្យខ្ញុំសន្និដ្ឋានយ៉ាងច្បាស់ថា គឺ ហ៊ុន-សែន និងកងអង្គរក្សរបស់គាត់នេះហើយ ដែលជាមនុស្សនៅពីក្រោយឧក្រិដ្ឋកម្មនេះ ។

នៅក្នុងរបាយកាណ៏នេះ មានសេចក្តីបញ្ជាក់នឹងបង្ហាញដោយសង្ខេប នូវពត៏មានទាំងអស់ដែលមានអំពីរឿងនេះ ។ មកទល់ពេលនេះ ពត៏មានទាំងអស់នោះ មិនទាន់ប្រមែប្រមូលចងក្រងជាឯកសារនៅឡើយទេ ហើយក៏ពុំទាន់បានផ្សព្វផ្សាយជាទូទៅនៅឡើយដែរ ។ ពត៏មានភាគច្រើននៅក្នុងរបាយការណ៏នេះ គឺបានមកពីប្រភពបីយ៉ាង :

១) ប្រភពមកពីក្រសួងស៊ើបអង្កេត របស់ប៉ូលីសសហព័ន្ធប្រទេសអាមេរិក ហៅថា FBI ដែលបានរាយការណ៏ទៅឲ្យសភាអាមេរិកាំង រួចបញ្ជូនទៅឲ្យគណកម្មការទំនាក់ទំនងការបរទេសព្រឹទ្ធសភា នៅថ្ងៃ២៤ ខែវិច្ឆិកា ១៩៩៨ ។

២) នៅថ្ងៃទី១៩ ខែកុម្ភៈ ១៩៩៩ សំបុត្ររបស់ FBI ផ្ញើទៅជូនលោកព្រឹទ្ធសភា ចេស្ស៊ី-ហែម (Jesse Helms) ហើយនិងសភាដំណាងរាស្ត្រ បិនចាមិន-ហ្គៀលមែន (Benjamin Gilman) គ្រិស្តូហ្វ័រ-ស្មិធ (Christopher Smith) និងលោក ដេណា-រោរ៉ាបេគ័រ (Dana Rohrabacher) ។

៣) ប្រភពចេញពីរបាយការណ៏ នាយប៉ូលីសខ្មែរសរសេរអក្សរដៃ នៅក្នុងខែឧសភា ១៩៩៧ ។ អត្ថបទក្នុងឯកសារទាំងបីប្រភពនេះ នឹងមានចុះនៅភាគខាងចុងនៃរបាយការណ៏នេះ ។

(<u>កំណត់សំគាល់</u> : របាយការណ៏របស់ប៉ូលីសខ្មែរ ហាក់ដូចជាមិនសូវច្បាស់លាស់ និងមិនមានលក្ខណៈត្រឹមត្រូវក្នុងការសរសេរ ម្យ៉ាងមកពីអ្នកបកប្រែ មិនសូវស្ទាត់ខាងភាសាអង្លេស ។ បើទោះជាយ៉ាងណាក៏ដោយ ក៏របាយការណ៏នោះ មានលក្ខណៈដូចគ្នាបេះបិទនឹង របាយការណ៏មកពី FBI ហើយនិង របាយការណ៏មកពីប្រភពផ្សេងៗទៀត ។

របាយការណ៍របស់ប៉ូលីសជាភាសាខ្មែរ គឺសំរាប់ការពារឈ្មោះសាក្សី និងការពារភ្នាក់ងារ FBI ។ ) សារពត៌មានក្រៅពីនេះទៀត គឺបានមកពីសារពត៌មានផ្សេងៗ ឬបានមកការសម្ភាសន៍ ជាមួយជានិងអ្នកចូលរួមក្នុងរឿងនេះ ដូចជា អ្នកត្រូវរបួស មន្ត្រីខ្មែរ អ្នកធ្វើការក្នុងអង្គារសិទ្ធិមនុស្ស ហើយនិងអ្នកសារពត៌មាន ។ សំនើបអង្កេតនេះ បានធ្វើឲ្យខ្ញុំ ធ្វើដំណើរពីរលើកទៅស្រុកខ្មែរ និងប្រទេសថៃ នៅក្នុងខែធ្នូ ១៩៩៨ ជាមួយលោក ស្តាហ្វដែល ដូរ៉ាន់ (Staffdel Doran) ហើយនៅក្នុងខែកក្កដា ១៩៩៩ ជាមួយលោក ស្តាហ្វដែល លោក បេកូវិច (Staffdel / Berkowitz) និង លោក ដូរ៉ាន់ (Doran) ។

នៅក្នុងលក្ខណៈជាពត៌មាន ឬជាឯកសារ វាអាចឬមិនអាច ជាភស្តុតាងគ្រប់គ្រាន់ដើម្បីកាត់ទោស ហ៊ុន-សែន ឬអ្នកនៅក្រោមបង្គាប់គាត់ ។ ក៏ប៉ុន្តែឯកសារទាំងបីប្រភេទ ដែលបានរៀបរាប់ដោយសង្ខេបមកហើយនេះ បានបង្ហាញប្រាប់យើងដោយខ្លួនឯង ។ អ្នកអានគួរតែជ្រាបថា ភស្តុតាងទាំងអស់នេះ បានឆ្លុះបញ្ចាំងពីអតិតកាលរបស់ ហ៊ុន-សែន ដែលតែងតែប្រើអំពើហឹង្សា ទៅអ្នកនយោបាយប្រឆាំងរបស់គាត់ ហើយអាចឲ្យយើងសន្និដ្ឋានដោយសុភវិនិច្ឆ័យបានថា ហ៊ុន-សែន នេះហើយ ដែលជាអ្នកទទួលខុសត្រូវទាំងស្រុង ក្នុងអំពើភេរវកម្មនេះ ។

មុននឹងបង្ហាញភស្តុតាងទាំងអស់នៅក្នុងរឿងនេះ ខ្ញុំសូមសង្ខេបពីប្រវត្តិខ្លះៗជាការចាំបាច់ ។

## II - ស្ថានភាពនយោបាយនៅប្រទេសកម្ពុជា

នៅពេលព្រឹត្តិការណ៍ថ្ងៃ៣០ មិនា ១៩៩៧ កើតឡើង ប្រទេសកម្ពុជាដឹកនាំដោយរដ្ឋាភិបាលក្បាលពីរគឺ មួយគណបក្សប្រជាជន (CPP) និងមួយទៀត គណបក្សរាជានិយម (FUNCINPEC) ។ គណបក្សប្រជាជន ដឹកនាំដោយរដ្ឋមន្ត្រីទីពីរ ហ៊ុន-សែន ចំណែកឯគណបក្សរាជានិយម ដឹកនាំដោយរដ្ឋមន្ត្រីទីមួយ នរោត្តម រណឫទ្ធិ ។ ឋានន្តរស័ក្តិនេះ គឺជាការបន្លំនិងបោកបញ្ឆោត ព្រោះថា ហ៊ុន-សែន និងគណបក្សប្រជាជនមានឥទ្ធិពលលើសលុប ក្នុងរដ្ឋាភិបាល ។ គណបក្សប្រជាជនមានដើមកំណើតចេញមកពី គណបក្សបដិវត្តិកម្ពុជា ដែលបង្កើតឡើងដោយសារកងកម្លាំងយួនឈ្លានពាននៅឆ្នាំ១៩៧៩ ។ ប្រទេសយួន, គណបក្សប្រជាជន, គណបក្សបដិវត្តិកម្ពុជា និង ហ៊ុន-សែន បានកាន់កាប់ត្រួតត្រាប្រទេសកម្ពុជាតាមរបបផ្តាច់ការនៅក្នុងទសវត្សរ៍១៩៨០ ហើយនៅពេលជាមួយគ្នានោះដែរ ពួករាជានិយម ពួកប្រជាធិបតេយ្យ និងកងទ័ពព្រៃខ្មែរក្រហម ក៏បានធ្វើសង្គ្រាមប្រឆាំងរដ្ឋាភិបាល ហ៊ុន-សែន ។ នៅក្នុងឆ្នាំ១៩៨៩ កងទ័ពយួនដកថយពីកម្ពុជា ទុកឲ្យ ហ៊ុន-សែន និងគណបក្សប្រជាជនត្រួតត្រាស្រុកខ្មែរ ។

នៅឆ្នាំ១៩៩១ រដ្ឋាភិបាល ហ៊ុន-សែន និងគូបដិបក្សប្រឆាំង បានចុះហត្ថលេខាលើកិច្ចសន្យាសន្តិភាព នៅក្រុងប៉ារីស ដែលបានបើកផ្លូវឲ្យអង្គារហសប្រជាជាតិ មានលទ្ធភាព ចូលមកត្រួតពិនិត្យការបោះឆ្នោត ឆ្នាំ១៩៩៣។ ព្រះអង្គម្ចាស់ រណឫទ្ធិ គណៈបក្ស FUNCINPEC និងសាខារបស់ខ្លួន បានឈ្នះសន្លឹកឆ្នោត៦២% ។ ចំណែកឯគណបក្សប្រជាជន បានសន្លឹកឆ្នោតត្រឹមតែ៣៨% ប៉ុណ្ណោះ។ ហ៊ុន-សែន បដិសេធមិនព្រមប្រគល់អំណាច ហើយថែមទាំងគម្រាមថានឹងប្រើកម្លាំងទ័ព ដើម្បីបង្កើតសង្គ្រាមស៊ីវិល ។

ដោយមានសញ្ញាយល់ព្រមពីអង្គារសហប្រជាជាតិផង រណឫទ្ធិ ក៏បានបង្ខំខ្លួន ទទួលគណបក្សប្រជាជន ឲ្យធ្វើជាសហរដ្ឋាភិបាលទៅ ។ នៅពេលនោះ សហរដ្ឋាភិបាល មាននៅក្នុងក្រដាស់ប៉ុណ្ណោះ ។ ហ៊ុន-សែន និងគណបក្សប្រជាជន នៅតែបន្តការត្រួតត្រា ដូចកាលពីឆ្នាំ១៩៧៩ ដដែល ។ ប្រភពអំណាចពិតប្រាកដនៅស្រុកខ្មែរ

គឺចុងកាំភ្លើង ។ នៅក្រោមសហរដ្ឋាភិបាល, ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ស្ថិតនៅក្នុងកណ្ដាប់ដៃរបស់គណបក្សប្រជាជនទាំងអស់ ។ ហ៊ុន-សែន ក៏មានកងអង្គរក្សផ្ទាល់ខ្លួនចំនួន២៥០០នាក់ ។ ពួកអង្គរក្សទាំងនោះធ្លាប់មានប្រវត្តិជាចោរ ធ្លាប់មានប្រវត្តិកាប់សម្លាប់ ប្រើអំពើហឹង្សា និងមិនមានការទទួលខុសត្រូវឡើយ ។ ពួកទាំងអស់នោះនឹងមានរាយនាម នៅភាគខាងចុងនៃរបាយការណ៍នេះ ។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុមុនគេបង្អស់ គឺលោក សម-រង្ស៊ី ។ ការខំប្រឹងប្រែងរបស់លោក សម-រង្ស៊ី នៅក្នុងរដ្ឋាភិបាលក្បាលពីរ ដើម្បីជីកឫសជីកគល់ បំបាត់អំពើពុករលួយ បានធ្វើឲ្យទំនាក់ទំនងរវាងរូបលោក និង ហ៊ុន-សែន ហើយនិង រណឫទ្ធិ មានសភាពតានតឹងឡើង រហូតដល់ដល់គេដក្សរូបលោកចេញពីមុខដំណែង នៅក្នុងខែតុលា ឆ្នាំ១៩៩៤ ។ បន្ទាប់ក្រោយមកបន្តិចលោក សម-រង្ស៊ី ក៏បានបង្កើតគណបក្សនយោបាយមួយ មានឈ្មោះថា គណបក្សជាតិខ្មែរ ។ គណបក្សនេះក៏បានក្លាយទៅជា គណបក្សប្រឆាំងដ៏ខ្លាំងក្លានៅកម្ពុជា ។ មកទល់នឹងពេលនេះ សម-រង្ស៊ី នៅតែប្រឆាំងនឹងរបបគ្រប់គ្រងរបស់ ហ៊ុន-សែន ដដែល ។ កាប្រជុំបាតុកម្មមហាជនថ្ងៃទី៣០ មិនា ១៩៩៧ នោះ គឺការសំដែងប្រកាសប្រឆាំងនឹងអំពើពុករលួយនៅក្នុងរបប និយាយរៀបចំប្រព័ន្ធតុលាការនៅស្រុកខ្មែរ ។ នៅថ្ងៃទី៤ ខែកក្កដា ១៩៩៧ ហ៊ុន-សែន បានធ្វើរដ្ឋប្រហារទំលាក់ រណឫទ្ធិ និងរបបរាជានិយម ហ្វុនស៊ីនប៉ិច (FUNCINPEC) ចេញពីអំណាច ។ រណឫទ្ធិ និងនាយទាហានរបស់ទ្រង់ បានត្រូវរត់គេចភៀសចេញក្រៅស្រុក ហើយមានសមាជិក ហ្វុនស៊ីនប៉ិច (FUNCINPEC) និងអ្នកគាំទ្រជាង១០០នាក់ បានត្រូវគេសម្លាប់ បន្ទាប់ពីរដ្ឋប្រហារមក ។ នៅដើមឆ្នាំ១៩៩៨ ប្រទេសជប៉ុន បានរៀបចំផែនការមួយ ដែលអនុញ្ញាតិឲ្យ រណឫទ្ធិ និង សម-រង្ស៊ី បានត្រឡប់ចូលមកស្រុកខ្មែរវិញ ដើម្បីចូលរួមបោះឆ្នោតជាថ្មីនៅថ្ងៃទី២៦ ខែកក្កដា ។ បន្ទាប់ពីមានការជជែកតវ៉ាមិនចុះសំរុងគ្នា ពីលទ្ធផលបោះឆ្នោតមក រដ្ឋាភិបាលថ្មីក៏បានបង្កើតឡើងនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៨ ដែលនៅក្នុងនោះ ហ៊ុន-សែន ធ្វើជានាយករដ្ឋមន្ត្រីតែម្នាក់ឯងគត់ ។ រណឫទ្ធិ ធ្វើជាប្រធានរដ្ឋសភា ហើយសមាជិក ហ្វុនស៊ិនប៉ិច (FUNCINPEC) ខ្លែះខ្លះៗបានធ្វើរដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាល ។ លោក សម-រង្ស៊ី បានធ្វើជាដំណាងរាស្ត្រ និងមានតួនាទីជា គណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ។

## អំពីការវិវត្តន៍ នៃសភាសហរដ្ឋអាមេរិក

នៅខែតុលា ១៩៩៧ លោកប្រធានាធិបតី បានចុះហត្ថលេខាលើច្បាប់សាធារណៈ លេខ១០៥-១១៨ គឺជាច្បាប់កិច្ចការបរទេសសំរាប់សារពើព័ន្ធឆ្នាំ១៩៩៨ ។ មាត្រាមួយនៃច្បាប់នោះ បានតម្រូវឲ្យលោកប្រធានាធិបតីធ្វើរបាយការណ៍របស់ក្រសួង FBI នៅក្នុងរឿងបោកគ្រាប់បែកនៅស្រុកខ្មែរ ។ របាយការណ៍ត្រូវតែបញ្ជូនឲ្យដល់សភាក្នុងរយៈពេល ៣០ថ្ងៃ ក៏ប៉ុន្តែទាល់តែដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៨ ទើបគណៈកម្មការទទួលបន្ទុករឿងនេះ បានទទួលរបាយការណ៍ ។

នៅចុងខែតុលា គណកម្មការទំនាក់ទំនងការបរទេសរបស់ព្រឹទ្ធសភា បានទទួលរបាយការណ៍មួយថែមទៀត ។ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៨ ព្រឹទ្ធសភា ចេស្ស៊ី-ហែម (Jesse Helms) នាយកគណកម្មការ បានសរសេរសំបុត្រទៅលោកប្រធានាធិបតី គឺដើម្បីសុំឲ្យលោកប្រធានាធិបតី បង្ហាញរបាយការណ៍ទាំងអស់នោះ ។ របាយការណ៍នោះដែលជារបាយការណ៍សង្ខេប នៃរបាយការណ៍ដើម ហើយចុះកាលបរិច្ឆេទថ្មី បានប្រគល់ផ្ទាល់ដៃ ឲ្យទៅគណកម្មការ

នៅថ្ងៃទី២៤ ខែតុលា ១៩៩៨ ដោយ FBI ។ ដោយពិនិត្យឃើញថា របាយការណ៍នោះហាក់ដូចជាមិនច្បាស់លាស់ លោកព្រឹទ្ធសភា ចេស្ស៊ី-ហែម (Jesse Helms) លោកសភាដំណាងរាស្ត្រ បឹនចាមិន-គ្គីលម៉ែន (Benjamin Gilman) លោក គ្រិស្តហ្វ័រ-ស្មិធ (Christopher Smith) ហើយនិងលោក ដេណា-រ៉ូរ៉ាបេគ័រ (Dana Rohrabacher) បាន សរសេរសំបុត្រមួយច្បាប់ ដោយដាក់សំណួរ២០សំនួរ ទៅលោកនាយក FBI ឈ្មោះ ល្វី-ហ្វ្រេស្ស (Louis Freeh) នៅ ថ្ងៃទី២៥ មករា ១៩៩៩ ។ FBI បានតបមកវិញនៅថ្ងៃ១៩ កុម្ភៈ ១៩៩៩ ។

## III - ការពិតជាក់ស្តែងក្នុងរឿងនេះ

ការពិតដូចតទៅនេះ គឺជាការពិតជាក់ស្តែង ដែលមិនអាចប្រកែកបានឡើយ ដោយគ្រាន់តែ FBI ធ្វើរបាយការណ៍ មិនបានគ្រប់សព្វ និងមិនបានច្បាស់លាស់ ហើយក៏មិនបានផ្សព្វផ្សាយទៅគ្រប់ទីសទី នៅក្នុងសហរដ្ឋអាមេរិក សូម្បីតែនៅវិមាន កាពីតូលហ៊ីល (Captitol Hill) ក៏មិនបានផ្សព្វផ្សាយដែរ ។

១- អ្នកទទួលខុសត្រូវនៅក្នុងបាតុកម្មប្រឆាំងនោះ គឺស្ថិតនៅលើកងប៉ូលីសក្រុងភ្នំពេញ ។ នៅពេលនោះ កងកម្លាំងប៉ូលីសក្រុងភ្នំពេញ គឺដឹកនាំដោយ ម៉ុក-ជីតូ ជាក្មួយរបស់ ហ៊ុន-សែន ។

២- នៅមុនពេលដែលក្រុមបាតុករបានប្រារព្ធផ្តើមប្រជុំ គេសង្កេតឃើញវត្តមានកងប៉ូលីសខុសប្លែកពីធម្មតា ។ ក្នុងចំណោមនាយប៉ូលីសទាំងនោះគឺមាន ម៉ុក-ជីតូ ដែលបានថតជារបៀបខ្សែភាពយន្ត នៅទីនោះ ។

៣- បន្ទាប់ពីបានអនុញ្ញាត ដែលជាសញ្ញាគ្រោងទុកជាមុនមក នាយប៉ូលីសបានដកថយពីទីលានប្រជុំ ហើយមាន កងកម្លាំងបួនក្រុមរបស់អង្គរក្សហ៊ុន-សែន (2nd Battalion, 17 Regiment, or “Unit #2”) បានរៀបជាខ្សែ តាមបណ្តោយទិសខាងលិច នៃឧទ្យានប្រជុំនោះ ។

៤- គេមិនដែលបានឃើញ គេយកកងកម្លាំងអង្គរក្សមកប្រើនៅពេលប្រជុំនយោបាយ របស់ប្រជាពលរដ្ឋ នៅស្រុកខ្មែរឡើយ ហើយក៏ពុំដែលឃើញគេយក កងកម្លាំងអង្គរក្សនោះមកប្រើ ក្នុងកិច្ចប្រជុំពីមុនៗចំនួន១៤ លើក ធ្វើឡើងដោយគណបក្សជាតិខ្មែរនោះដែរ ។

៥- បន្ទាប់ពីបានបោកគ្រាប់បែកនោះមក យ៉ាងហោចណាស់ក៏មានមនុស្សពីរនាក់ដែរ ដែលបានរត់គេចខ្លួន ដោយជើង រត់តាមខ្សែត្រៀមកងអង្គរក្ស សំដៅទៅមជ្ឈមណ្ឌលគណបក្សប្រជាជន នៅជិតនោះ ។

៦- មន្ត្រីគណបក្សប្រជាជន មិនព្រមចូលរួមក្នុងការស៊ើបអង្កេត ។ លោក តេង-សារ៉ុន ប្រធានគណកម្មការ ស៊ើបអង្កេត បានបដិសេធមិនព្រមឲ្យ FBI ជួប ម៉ុក-ជីតូ មេប៉ូលីស ហើយត្រូវជាក្មួយ ហ៊ុន-សែន ។ អគ្គមេបញ្ជាការកងអង្គរក្សឈ្មោះ ហ៊ុយ-ពិសិដ្ឋ បានបដិសេធដោយនិយាយថា គាត់មិនបានឃើញ មិនបាន

ដឹងឮអ្វីទាំងអស់ដែល FBI និយាយថាជាការមិនចូលរួម ក្នុងអង្កេតការនោះឡើយ ។ ស-ខេង រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ បដិសេធមិនឲ្យ FBI ធ្វើសម្ភាសន៍ជនសង្ស័យម្នាក់ឈ្មោះ Brasil ។

៧- កងកម្លាំងអង្គរក្សក្រុមលេខ២ បានទទួលបញ្ជាពី ហ៊ុយ-ពិសិដ្ឋ ឬពី ហ៊ុន-សែន ខ្លួនឯង ។ ហ៊ុយ-ពិសិដ្ឋ បាននិយាយជាច្រើនដងថា គាត់បានទទួលបញ្ជាឲ្យបោកគ្រាប់បែក ។ មានពេលខ្លះ គាត់និយាយថា បទបញ្ជា បានចេញមកខុទ្ទកាល័យរបស់ ហ៊ុន-សែន ។ បើយោលទៅតាមលក្ខណៈមិនអាចប្រកែកបាននេះ នោះយើង ឃើញថា យើងនឹងពិបាកជឿថា មាននរណាផ្សេងទៀតក្រៅពី ហ៊ុន-សែន ដែលបានបញ្ជាឲ្យបោកគ្រាប់បែក នេះ ។ នៅមានភស្តុតាងជាច្រើនទៀត ដើម្បីយកមកបង្ហាញក្នុងករណីយនេះ ។

## សម្ភាភាព

នៅដើមខែមិថុនា ១៩៩៨ មានមនុស្ស២នាក់ គឺលោក ឆាយ-វី និងលោក ជុំ-ប៊ុនធឿន បានចូលមកសារភាពក្នុង រឿងបោកគ្រាប់បែកនេះ ។ ដំបូងអ្នកទាំង២បានសារភាព ដោយបង្ហាញតាមខ្សែកុន (Videotaped) ទៅអ្នកគណបក្ស សម-រង្ស៊ី ហើយបានប្រាប់ថា ហ៊ឹម-ប៊ុនហ៊ាង ដែលជាភ្នួឈ្នួយរបស់លោក ពិសិដ្ឋ បានឲ្យលុយគាត់ទាំង២នាក់ ដើម្បី បោះគ្រាប់បែកទៅលើលោក សម-រង្ស៊ី ។ អ្នកទាំង២បាននិយាយថា គេបានព្រមព្រៀងមកដល់ចំណុចមួយ ព្រោះខ្លាច កងអង្គរក្សហ៊ុន-សែន សម្លាប់ បើសិនជាបេសកកម្មរបស់គេត្រូវបរាជ័យ ។ នៅខែកុម្ភៈ ១៩៩៩ ខ្សែអាត់កុននេះ បានចាក់មើលឡើងវិញ នៅក្នុងវិមានកាពីតូលហ៊ីល (Capitol Hill) នៅចំពោះមុខជនជាតិខ្មែរចូលសញ្ជាតិអាមេរិកាំង២ នាក់ ដែលជួយបកប្រែខ្សែអាត់នោះ ។ លុះដល់គេសួរអ្នកបកប្រែទាំង២នាក់ អំពីរឿងពិតរបស់មនុស្សសង្ស័យទាំង២ នោះ ម្នាក់ៗបានឆ្លើយរៀងៗខ្លួនថា ឆាយ-វី និង ជុំ-ប៊ុនធឿន ជាមនុស្សគួរឲ្យជឿមែន ហើយអ្នកទាំង២ហាក់ដូចជា ខ្លាចគេសម្លាប់មែន ។ បន្ទាប់មកទៀត ឆាយ-វី និង ជុំ-ប៊ុនធឿន ក៏បានសារភាពនៅចំពោះមុខស្នងការសហប្រជា ជាតិផ្នែកសិទ្ធិមនុស្សនៅភ្នំពេញ ហើយនៅថ្ងៃទី៤ មិថុនា ១៩៩៧ លោក សម-រង្ស៊ី បានទៅជួប FBI នៅបាងកក ដែលនៅទីនោះ គេទាំង២នាក់បាននិយាយសារភាពដូចគ្នា ។

## ជនជាប់សង្ស័យឈ្មោះ ប្រេស៊ីល (Brazil)

បើយោលទៅតាមរបាយការណ៍ FBI ការមន្ទិលសង្ស័យជាចំបង នៅក្នុងរឿងនេះ គឺមនុស្សមិនស្គាល់មុខម្នាក់ឈ្មោះ ប្រេស៊ីល (Brasil) ។ គឺនៅក្នុងរយៈពេលដ៏ខ្លីក្នុងខែមិថុនា ១៩៩៧ មនុស្សឈ្មោះ ប្រេស៊ីល នេះ បានឋិតនៅក្នុងការ ឃុំគ្រងរបស់ឧត្តមសេនីយ ញឹក-ប៊ុនឆាយ ដែលឧត្តមសេនីយនេះបានធ្វើសម្ភាសន៍ និងបានថតខ្សែអាត់កុន ហើយនិង បានចម្លងខ្សែអាត់នោះ និងឯកសារទាក់ទងឯទៀតៗ ឲ្យទៅសារទូតសហរដ្ឋអាមេរិកប្រចាំក្រុងភ្នំពេញ ។ FBI បាន បញ្ជាក់ថា គេបានទទួលខ្សែអាត់មួយ ហើយគឺពិតជានិយាយដោយ ប្រេស៊ីល មែន ។ ប្រេស៊ីល បានរត់គេចពី ឃុំឃាំងនៅដើមខែកក្កដា ១៩៩៧ ប្រហែលនៅពេល ហ៊ុន-សែន ធ្វើរដ្ឋប្រហារ ហើយឥឡូវនេះគេមិនដឹងថា ប្រេស៊ីល នៅឯណាទេ បើតាម FBI និយាយ ។ នៅពេលដែលលោក ស្តាហ្វដែល-ដូរ៉ាន់ (Staffdel Doran) បាន សម្ភាសន៍លោកឧត្តមសេនីយ ញឹក-ប៊ុនឆាយ នៅបាងកកក្នុងខែធ្នូ ១៩៩៨ គាត់បាននិយាយថា ប្រវត្តិ ប្រេស៊ីល នេះ

មានការសំខាន់ដូចគ្នានិងប្រវត្តិរបស់ ឆាយ-វី និង ជុំ-ប៊ុនធឿន ។ កងកម្លាំងអង្គរក្ស ហ៊ុន-សែន បានជួល ប្រេស៊ីល ឲ្យបោះគ្រាប់បែកទៅលើ សម-រង្ស៊ី ។ ប្រេស៊ីល ក៏បានប្រាប់លោកឧត្តមសេនីយ ញឹក-ប៊ុនឆាយ ផងដែរ ថា គេបានរៀបចំផែនការណ៍ជាមួយ ឆាយ-វី និង ជុំ-ប៊ុនធឿន អំពីការវាយប្រហារ ហើយនេះជាលើកទី៣ហើយ ដែលគេចង់សម្លាប់លោក សម-រង្ស៊ី ។

## រឿងបញ្ជាក់ផ្សេងទៀត : របាយការណ៍របស់ប៉ូលីសខ្មែរ នៅខែមិនា ១៩៩៧

ដោយយោលទៅតាមរបាយការណ៍របស់ប៉ូលីសខ្មែរ នៅខែមិនា ១៩៩៧ ភ្នាក់ងារ FBI បានដកស្រង់សំដីថា: “មនុស្ស ដែលបានបោះគ្រាប់បែកនោះ មិនមែនជាមនុស្សធម្មតាទេ ។ មនុស្សទាំងនោះជាទាហាន ហ៊ុន-សែន” ។ សាក្សីបានឃើញមនុស្សទីមួយ បានងាកមកមើលកងកម្លាំងអង្គរក្សជាមុនសិន មុននឹងបោះគ្រាប់បែក ។ កងពល អង្គរក្សបានឈរជាខ្សែ ដើម្បីការពារមជ្ឈមណ្ឌលគណបក្សប្រជាជន ហើយអ្នកដែលឈរយាមមាត់មជ្ឈមណ្ឌលនោះ បានបើកទ្វារ ដើម្បីឲ្យមនុស្សប្រព្រឹត្តិបទឧក្រិដ្ឋនោះ រត់ចូល ។ FBI បានបដិសេធថា ពាក្យសំដីខាងលើនេះ មិនមែន និយាយដោយភ្នាក់ងាររបស់គេឡើយ ។ ប៉ុន្តែរបាយការរបស់ប៉ូលីសខ្មែរ មានលក្ខណៈដូចគ្នានឹងរឿងដែលសាព៌ាមាន Washington Post បានចុះផ្សាយនៅថ្ងៃទី២៧ ខែមិថុនា ១៩៩៧ ដែលបានផ្សាយថា របាយការណ៍ជាលើកដំបូង ថាមានមន្ត្រីផ្លូវការរដ្ឋាភិបាលអាមេរិកាំងបួននាក់ បានធ្លាប់ឮរឿងនេះដែរ ហើយដែលរបាយការសម្ងាត់ FBI បានចង្អុល ទៅលើកងកម្លាំងអង្គរក្ស ហ៊ុន-សែន នោះដែរ ។

របាយការណ៍ប៉ូលីសខ្មែរ មានលក្ខណៈដូចគ្នានិងអ្នកដែលបានឃើញ អំពីរបៀបដែលឧក្រិដ្ឋជន បានរត់សំដៅទៅ មជ្ឈមណ្ឌល CPP ។ កងអង្គរក្សហ៊ុន-សែន មិនគ្រាន់តែជួយឲ្យឧក្រិដ្ឋជនរត់គេចខ្លួនប៉ុណ្ណោះទេ ថែមទាំងបានឃាត់ ឃាំងអ្នកគាំទ្រលោក សម-រង្ស៊ី មិនឲ្យដេញតាមចាប់អ្នកបោះគ្រាប់បែកនោះថែមទៀតផង ។ របាយការណ៍បានបន្ត ទៀតថា នាយទាហានហ៊ុន-សែន មិនព្រមចូលរួមសហប្រតិបត្តិការក្នុងការធ្វើអង្កេតទេ ។ នៅក្នុងពេលនោះ ពេល វេលាជាច្រើនដែលឥតប្រយោជន៏ ព្រោះថា តេង-សាវុន ប្រធានស៊ើបអង្កេតរបស់ CPP នៅតែនិយាយទទួចពីរឿង ប្រឆាំងនឹងលោក សម-រង្ស៊ី ។ រឿងមួយទៀតបានឲ្យយើងនឹកឃើញថា ហេតុដូចម្តេចបានជាលោក ពិសិដ្ឋ បានបញ្ជា ឲ្យលោក ឈិន-សាវុន មេបញ្ជាការអង្គរក្ស ប្រចាំទីលានបោកគ្រាប់បែក ឈប់និយាយជាមួយ FBI នៅថ្ងៃទី៨ ឧសភា នៅពេលដែលលោក ឈិន-សាវុន កំពុងចាប់ផ្តើមពន្យល់ FBI អំពីរបៀបដែលកូនទាហានរបស់គាត់ បានបោះគ្រាប់បែក ។ នៅពេលខ្លះទៀត លោក ហ៊ឹម-ប៊ុនហ៊ាង ភ្ញូឈ្លួយលោក ពិសិដ្ឋ បាននិយាយកាត់ ហើយ ឃាត់លោក ពិសិដ្ឋ ឲ្យឈប់និយាយ នៅពេលដែលលោក ពិសិដ្ឋ បំរុងនឹងនិយាយប្រាប់ FBI អំពីមនុស្សដែលបាន បញ្ជាគាត់ ឲ្យរៀបចំគំរោងការបោះគ្រាប់បែក នៅថ្ងៃទី៣០ មិនា ។ របាយការណ៍បានបង្ហាញផងដែរថា តើយ៉ាងដូច ម្តេច បានជាឧក្រិដ្ឋជន២នាក់ បានត្រូវនាំចេញពីកន្លែងបោកគ្រាប់បែក ដោយមានការហែហមគាំទ្រពីមនុស្សរបស់ ហ៊ុន-សែន ។ តាមរបាយការណ៍ ប្រហែលជានៅម៉ោង២រសៀល ក្នុងថ្ងៃបោកគ្រាប់បែក មានឧទ្ធម្ភាគចក្រមួយគ្រឿង បាន ចុះចតនៅក្បែរសួនឧទ្យានជា-ស៊ីម នៅភ្នំពេញ ។ សួនឧទ្យាននោះ ស្ថិតនៅជិតបង្គើយនឹងកន្លែងបោកគ្រាប់បែក ។ មានរថយន្តតូយ៉ូតាឡិនគ្រូស័រ (Toyota Landcruisers) ជាច្រើនគ្រឿង នៅរង់ចាំឧទ្ធម្ភាគចក្រនោះ ហើយគេ ឃើញរថយន្តមួយដែលមានលោក ហ៊ឹម-ប៊ុនហ៊ាង ជិះជាមួយនិងមនុស្ស២នាក់ទៀត មានរូបរាងប្រហាក់ប្រហែលនឹង

មនុស្សដែលគេសង្ស័យ ។ គឺ ហ៊ឹម-ប៊ុនហ៊ាង នេះហើយ ដែលបានឃាត់លោក ពិសិដ្ឋ មិនឲ្យធ្វើសម្ភាសន៍ជាមួយ FBI ហើយដែល ឆាយ-វី និង ជុំ-ប៊ុនធឿន បានសារភាពថា ហ៊ឹម-ប៊ុនហ៊ាង នេះបានជ្រើសរើសគេទាំង២ឲ្យបោកគ្រាប់បែក ។ បន្ទាប់ពីឧទ្ទម្ភាគចក្របានចុះចតមក មនុស្សសង្ស័យទាំង២ ក៏បានឡើងជិះឧទ្ទម្ភាចក្រជាមួយលោក គុន-គឹម (Kun Kim) ភូឈ្មួយអភិបាលខេត្តកណ្តាល ហើយជាមិត្រជិតស្និទ្ធ ហ៊ុន-សែន ។ រីឯរឿងដែលថាឧទ្ទម្ភាគចក្រមានគ្រោះថ្នាក់នោះ គេមិនឃើញមាននៅក្នុងរបាយការណ៍របស់ FBI នោះឡើយ ។ នៅពេលឆ្លើយតបនឹងសំណួររបស់សភាសហរដ្ឋអាមេរិកាំងក្នុងរឿងនេះ FBI បានឆ្លើយថាលោក តេង-សាវុន បានប្រាប់ថា រឿងនោះគឺជាពត៌មានមិនពិតឡើយ ។ រឿងមួយដែលមិនគួរជឿគឺរឿងដែល FBI ទទួលយកការអះអាងរបស់ តេង-សាវុន ។ នៅពេលកំពុងស្វែងរកការពិត អំពីគ្រោះថ្នាក់ឧទ្ទម្ភាគចក្រនោះ លោក តេង-សាវុន បានបដិសេធមិនព្រមពន្យល់ពីរឿងនេះទេ ។ នេះសឲ្យឃើញថា គាត់មិនព្រមធ្វើសហប្រតិបត្តិការ ក្នុងកិច្ចការស៊ើបអង្កេតនោះឡើយ ។ ពត៌មានខាងលើនេះ គឺជាភស្តុតាងមួយបង្ហាញថា កងកម្លាំងអង្គរក្ស ហ៊ុន-សែន មានការពាក់ព័ន្ធក្នុងរឿងបោកគ្រាប់បែកលើលោក សម-រង្ស៊ី មែន ។ ប្រសិនបើគ្មានយោបល់ ឬទ្រឹស្តីណាផ្សេងទៀត ដែលអាចបដិសេធរឿងពិតនេះបានទេនោះ គឺថាការឃុបឃិត របស់ ហ៊ុន-សែន ជាភស្តុតាងមិនអាចប្រកែកបានឡើយ ។

## យោបល់ ឬទ្រឹស្តីផ្សេងៗទៀត :

មានទ្រឹស្តី ឬគំនិតនិងយោបល់តែបន្តិចបន្តួចប៉ុណ្ណោះ ដែលអាចនិយាយបដិសេធការពិតនេះ ។ ក៏ប៉ុន្តែគំនិតទាំងអស់នោះ គ្រាន់តែនិយាយឥតមានភស្តុតាងបញ្ជាក់សោះឡើយ ។ ទ្រឹស្តីទី១ បានលើកឡើងបន្ទាប់ពីការបោកគ្រាប់បែក ថាលោក សម-រង្ស៊ី ខ្លួនឯងនេះហើយ ដែលបានរៀបចំបោកគ្រាប់បែក ទៅលើខ្លួនឯង ។ ក្រៅពីសំដី ហ៊ុន-សែន ដែលបាននិយាយដូចនេះមក គឺគ្មានភស្តុតាងអ្វីផ្សេងបន្តិចបន្តួចទាល់តែសោះ ដើម្បីគាំទ្រការចោទប្រកាន់នេះ ។ តាមការពិត FBI មានឱកាសល្អច្រើនណាស់ ដើម្បីបង្ហាញភ័ស្តុតាង តែពុំព្រមធ្វើដូច្នោះឡើយ ។ នៅក្នុងសំបុត្រផ្ញើទៅលោកនាយក FBI ឈ្មោះ ហ្វ្រី (Freeh) លោកព្រឹទ្ធសភា ហែមស៍ (Senator Helms) និងលោកសភាតំណាងរាស្ត្រ ហ្គីលមែន (Congressmen Gilman) លោក ស្ម៊ីធ (Smith) និងលោក រ៉ូរ៉ាបេគ័រ (Rohrabacher) បានដាក់ជាសំណួរ ដូចតទៅនេះ :

"នៅទំព័រទី៩, របាយការណ៍បាននិយាយថា លោក សម-រង្ស៊ី មានការភិតភ័យ កាលបើបានដំណឹងថា FBI បំរុងនឹងសួរគាត់ អំពីការចោទប្រកាន់ នឹងគំនិតដែលជំរុញឲ្យបោកគ្រាប់បែក ។"

តើសំណួរនោះសួរដូចម្តេចខ្លះ? តើនេះជាសំដីបញ្ឆិតបញ្ឆៀង ដែលនិយាយថា លោក សម-រង្ស៊ី បានបោកគ្រាប់បែកនោះ? ចុះហេតុដូចម្តេចបានជាមិននិយាយ រៀបរាប់នៅក្នុងរបាយការណ៍?

## ចម្លើយ FBI មានដូចតទៅនេះ :

"សំដីទាំងអស់នោះ មិនមែនជាសំដីរបស់ភ្នាក់ងារស៊ើបអង្កេតនោះទេ ហើយក៏មិនមាននៅក្នុងរបាយការណ៍នោះដែរ ។"

កាលណាគណកម្មការទំនាក់ទំនងបរទេសរបស់ព្រឹទ្ធសភាបានទទួលចម្លើយពី FBI របាយការណ៍ត្រូវបានពិនិត្យចំនួន២លើក ព្រោះខ្មាចក្រែងអ្នកអានមើលច្រឡំ ។ ទេ, មិនមែនមើល ឬអានច្រឡំទេ ។ សំដីដែលដកស្រង់នៅក្នុងទំព័រទី៩, វគ្គទី៤, បន្ទាត់ទី៤ និងវគ្គទី៥ ក្នុងរបាយការណ៍ FBI (សេចក្តីបន្ថែមទី១) ។ ដោយហេតុថា FBI មិនបានឆ្លើយនឹងសំណួរនេះដោយត្រង់ និងត្រឹមត្រូវទេនោះ, គេអាចសន្និដ្ឋានបានថា FBI មិនមានភស្តុតាងអ្វីច្បាស់លាស់ ដែលចោទលោក សម-រង្ស៊ី មានការពាក់ព័ន្ធក្នុងការបោកគ្រាប់បែកនោះ ។

អង្គរក្សលោកសម-រង្ស៊ី ម្នាក់បានស្លាប់ក្នុងពេលនោះ ។ មិត្តដ៏ល្អរបស់គាត់ម្នាក់ឈ្មោះ រ៉ុន-អាប់នី (Ron Abney) បានត្រូវរបួសយ៉ាងដំណំ ។ នេះបង្ហាញឲ្យឃើញថា លោក សម-រង្ស៊ី នៅគ្រប់ដំណើរទាំងអស់, លើកលែងតែហ៊ុន-សែន និងបរិវារ, មិនបានប្រព្រឹតឧក្រិដ្ឋកម្មនេះឡើយ ។

ទ្រឹស្តីមួយទៀតនិយាយថា ការបោកគ្រាប់បែកនេះ គឺបានធ្វើចេញមកពីក្នុងគណៈបក្សលោក សម-រង្ស៊ី ។ ទ្រឹស្តីនេះមានប្រភពចេញមកពី អតីតអគ្គរដ្ឋទូតសហរដ្ឋអាមេរិកាំងម្នាក់ ប្រចាំក្រុងភ្នំពេញ ឈ្មោះលោក ខឹន-ឃ្វិន (Ken Quinn) នៅក្នុងកិច្ចការប្រជុំមួយ ជាមួយលោក Staffdel Berowitz/Doran នៅថ្ងៃទី៥ មិថុនា ១៩៩៩ ។ លោកអគ្គរដ្ឋទូតនេះបាននិយាយថា រដ្ឋាភិបាលបារាំង មានការចាប់អារម្មណ៍ទៅលើសមាជិកគណៈបក្ស សម-រង្ស៊ី ម្នាក់ឈ្មោះ អ៊ិន-ថាត់ឌី (In Thaddee), គឺជាមនុស្សមានសញ្ជាតិបារាំង-ខ្មែរម្នាក់ ។ លោកអគ្គទូតបាននិយាយទៀតថា លោក អ៊ិន-ថាត់ឌី នេះ មានគ្រួសារជាប់ទាក់ទងនឹងខ្មែរក្រហម ហើយដែលមានប្រវត្តិចូលចិត្តធ្វើអំពើឃោរឃៅ ។ លោក Staffdel Berkowitz/Doran បានទៅជួបនឹងលោក អ៊ិន-ថាត់ឌី នៅថ្ងៃទី៦ មិថុនា ១៩៩៩ ។ គណប្រតិភូមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើគាត់ ដោយ ថាត់ឌី ជាមនុស្សចេះដឹងយ៉ាងខ្ពស់ ហើយច្បាស់លាស់ទៀតផង ។ កាលណាសួរគាត់ពីពាក្យ “ចចាមអារាម” ដែលថាគាត់ជាមនុស្សជាប់សង្ស័យក្នុងការបោកគ្រាប់បែកនោះ, លោក ថាត់ឌី បានឆ្លើយយ៉ាងចំហ, ស្មោះត្រង់ ហើយមិនមានអ្វីលាក់លៀមឡើយ ។ គាត់បានប្រាប់ប្រតិភូថា ពាក្យ “ចចាមអារាម” នោះ មិនមែនជារឿងថ្មីអ្វីទេ, គាត់បានត្រូវគេចុះក្នុងសាព៌មានភ្នំពេញប៉ុសតិ៍ (Phnom Penh Post) ជាប់ជាមនុស្សសង្ស័យបន្ទាប់ពីបោកគ្រាប់បែក រួចមកហើយរដ្ឋាភិបាលក៏បានសួរចម្លើយគាត់ម្តងទៀតផង ។ លោក ថាត់ឌី ហាក់ដូចជាមានការអស់សំណើច ដែលឮថាពាក្យ “ចចាមអារាម” នេះនៅតែមានដដែល ហើយបាននិយាយថា គាត់មិនបានធ្វើដូច្នោះឡើយ ។ ឮគេនិយាយចំនួន២ឆ្នាំមកហើយ ហើយគ្មានរដ្ឋាភិបាលបារាំង ឬរដ្ឋាភិបាលខ្មែរណាមកសួរដេញដោល គឺទើបតែបន្ទាប់ពីបោកគ្រាប់បែកមកប៉ុណ្ណោះ ។ លោក ថាត់ឌី ជាមនុស្សស្មោះត្រង់ និងមិនលាក់លៀមអំពីទំនាក់ទំនងរវាងគ្រួសារគាត់នឹងខ្មែរក្រហម ។ ឪពុកមាគាត់ជាមេខ្មែរក្រហម, ក៏ប៉ុន្តែនេះក៏មិនអាចរារាំង ឬហាមចិត្តគាត់បាន ក្នុងការគាំទ្រតុលាការអន្តរជាតិ ដើម្បីយកមេខ្មែរក្រហមទៅកាត់ទោសនោះឡើយ ។ ចំណែកឯលោក សម-រង្ស៊ី វិញ, គាត់នឹកទៅគួរឲ្យអស់សំណើច អំពីការចោទប្រកាន់នោះ ។ ដោយហេតុថា FBI ក្តី ឬប្រភពឯទៀតផ្សេងក្តី មិនបានចុះទ្រឹស្តីនេះនៅក្នុងរបាយការណ៍នេះឡើយ ។ ដូច្នេះទ្រឹស្តីទាំងអស់នេះ មិនគួរឲ្យជឿបានជាដាច់ខាត ។

មានទ្រឹស្តីផ្សេងទៀតនិយាយថា ខ្មែរក្រហមជាអ្នកទទួលខុសត្រូវ (សមាជិកគណបក្សប្រជាជនខ្លះ បានចោទយ៉ាងដូច្នេះ) ហើយថាបានរៀបចំបោកគ្រាប់បែក ដើម្បីធ្វើឲ្យជឿថា ហ៊ុន-សែន ឬក៏គណបក្សប្រជាជនបានធ្វើ (គំនិតនេះនិយាយចេញមកពី អគ្គរដ្ឋទូតអាមេរិកាំងឈ្មោះលោក ឃ្វីន នៅថ្ងៃទី៥ ខែកក្កដា ។ គ្មានទ្រឹស្តីណាមួយដែលគួរឲ្យជឿ

នោះឡើយ ។ ពួកខ្មែរក្រហមបានត្រូវថយចុះនូវចំនួនរបស់ខ្លួន ព្រមទាំងចុះខ្សោយខាងអំណាចនៅខែមិនា ១៩៩៧ ហើយក៏មិនដែលបានធ្វើភេរវកម្មនៅតាមជាយក្រុងឡើយ ។ រៀបចំបោកគ្រាប់បែកប្រយុទ្ធដើម្បីបង្ខូចនរណាម្នាក់នោះ គឺត្រូវការធនធាន ឬលុយយ៉ាងច្រើន ដែលមិនអាចមានដល់ជនណាក្រៅពីអ្នកកាន់អំណាចនៅស្រុកខ្មែរ ហើយអ្នកកាន់អំណាចនៅស្រុកខ្មែរសព្វថ្ងៃនេះគឺ ហ៊ុន-សែន និងគណបក្សប្រជាជន ដែលកាន់កាប់ស្រុកខ្មែរតាំងពី២០ឆ្នាំមកម្ល៉េះ ។ នៅក្នុងករណីយទាំងអស់នេះ គ្មានទ្រឹស្ដីណាមួយដែលមានភស្តុតាងច្បាស់លាស់នោះឡើយ ។

## IV – នាទីរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក

ដូចបានអធិប្បាយខាងដើមមកហើយ ក្រសួងការពារប្រទេស ឬក្រសួង FBI ឥតបានឲ្យដំណឹងនេះទៅសភាជាតិអាមេរិក លោក សម-រង្ស៊ី ឬសាធារណជនបានដឹងឡើយនៅថ្ងៃទី២៧ ខែកញ្ញា ១៩៩៩ ។

## របាយការណ៍ FBI: គ្រាន់តែជាការស្នាក់ស្ទើរ ឬជាដំណឹងមិនច្បាស់លាស់?

អស់រយៈពេល២ឆ្នាំកន្លះមកហើយ ដែល FBI មិនទាន់រកឃើញឧក្រិដ្ឋជននៅឡើយ ។ នេះមិនមែនជារឿងធម្មតានោះទេ, FBI មិនព្រមធ្វើរបាយការណ៍ និងមិនព្រមពន្យល់សភាជាតិ ហើយក៏មិនព្រមធ្វើវិភាគ លើលទ្ធផលរកឃើញ ឬណែនាំថា តើលទ្ធផលអង្កេតការណ៍នោះ នឹងទៅជាយ៉ាងណា ។ នៅក្នុងសេចក្ដីពន្យល់ ទៅបុគ្គលិកគណកម្មការព្រឹទ្ធសភាទំនាក់ទំនងកិច្ចការបរទេស ក្នុងខែកុម្ភៈ ១៩៩៩, មន្ត្រីផ្លូវការ FBI បានបដិសេធមិនព្រមប្រាប់ថា តើនរណាជាអ្នកនៅពីក្រោយការបោកគ្រាប់បែក ហើយហាក់ដូចជាចង់ណែនាំថា ទ្រឹស្ដីទាំងឡាយដែលបានរៀបរាប់មក នោះមានលក្ខណៈគួរឲ្យជឿបាន ។ ដូចដែលបានបង្ហាញខាងដើមរួចមកហើយ, FBI ជាក្រសួងដ៏ធំមួយដែលអាចរក ការពិត (លើកលែងតែ FBI បានទទួលភស្តុតាង ឬទ្រឹស្ដីផ្សេងទៀតពីរដ្ឋសភា) ។ FBI មានភស្តុតាងគ្រប់គ្រាន់នៅចុង ខែឧសភា ១៩៩៧ ដើម្បីសន្និដ្ឋានថា ហ៊ុន-សែន ជាអ្នកមានទោស ។ FBI ក៏មានពេលជាងមួយឆ្នាំ ក្នុងការវិនិច្ឆ័យទៅលើសំណារភាពគួរឲ្យជឿបានរបស់ ឆាយ-វី និង ជុំ-ប៊ុនធឿន នៅខែមិថុនា ១៩៩៨, ក៏ប៉ុន្តែពុំបានធ្វើដូច្នោះឡើយ ។ ដូចជាពិបាកជឿដែរដែលថា FBI រកមិនឃើញមនុស្សនៅពីក្រោយការបោះគ្រាប់បែកមកដល់ពេលនេះ ។ នាទីរបស់ FBI នៅក្នុងរឿងនេះ គឺមិនមែនស្ថិតនៅលើការគ្មានសមត្ថភាព ឬក៏មិនចង់បង្ហាញឈ្មោះ ឬចាប់ឧក្រិដ្ឋជននោះឡើយ ។ FBI ធ្វើទៅតាមលក្ខណៈច្បាប់ ហើយអាចនឹងមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីចាប់ ហ៊ុន-សែន ឬមនុស្សណាផ្សេងទៀត ។ ការព្រួយបារម្ភធំបំផុត គឺស្ថិតនៅលើការធ្វេសប្រហែស និងមិនស្វែរយកចិត្តទុកដាក់ ដែល FBI បានធ្វើក្នុងការស៊ើបអង្កេតទាំងមូល, យ៉ាងហោចណាស់ចាប់តាំងពីខែមិថុនា ១៩៩៧ មក ។

## បរាជ័យក្នុងរឿង ឆាយ-វី និង ជុំ-ប៊ុនធឿន

ឧទាហរណ៍ជាក់ស្ដែងនៅក្នុងរឿងនេះ គឺអំពើការកាន់ក្ដាប់សំណារភាពរបស់ ឆាយ-វី / ជុំ-ប៊ុនធឿន ។ ដូចបានកត់សំគាល់ខាងលើស្រាប់, FBI បានធ្វើសម្ភាសន៍មនុស្សទាំង២នាក់នោះនៅថ្ងៃទី៤ ខែមិថុនា ១៩៩៨, នៅក្នុងរឿងនេះ គេបានសារភាពថា បានចូលរួមក្នុងការបោកគ្រាប់បែកនោះ ក្រោមកិច្ចបញ្ជារបស់ ហ៊ឹម-ប៊ុនហ៊ាង ដែលជាអង្គរក្សម្នាក់របស់ ហ៊ុន-សែន ។ សំណារភាពនេះបានអធិប្បាយពន្យល់នៅក្នុងទំព័រ១២ នៃរបាយការណ៍ FBI ។ ក៏ប៉ុន្តែនៅវគ្គ

បន្ទាប់, FBI បានរាយរ៉ាប់នៅថ្ងៃ១៣ ខែវិច្ឆិកា ១៩៩៨ អំពីការធ្វើសម្ភាសន៍សាជាថ្មីឡើងវិញ ។ នៅពេលនោះ ឆាយ-វី និង ជុំ-ប៊ុនធឿន បានដូរគំនិត ហើយឆ្លើយបដិសេធពីរឿងបោកគ្រាប់បែកនេះ ។ ម្យ៉ាងទៀតមនុស្សទាំង២ នាក់នេះបានចោទថា គេបានសារភាពនៅខែមិថុនានោះ ព្រោះមន្ត្រីផ្លូវការរបស់គណបក្សលោក សម-រង្ស៊ី បានឲ្យ លុយគេម្នាក់ៗ ១៥,០០០ ដុល្លា ។ ដោយមិនមានការពន្យល់វែងឆ្ងាយតទៅទៀតនោះ, របាយការណ៍របស់ FBI បាន ទទួលយកពាក្យបដិសេធន៍របស់ ឆាយ-វី និង ជុំ-ប៊ុនធឿន ទៅវិញហើយ បែរជាមិនទទួលយកពាក្យសារភាពខាង ដើមនោះឡើយ ។ គឺមិនគួរឲ្យជឿសោះដែល FBI បានភ្លេចថា ឆាយ-វី និង ជុំ-ប៊ុនធឿន បានជាប់ឃុំឃាំងក្នុង ប៉ុស្តិ៍ប៉ូលីសហ៊ុន-សែន នៅខែសីហា ១៩៩៨ ។ គឺជាការពិតណាស់ ដែលប៉ូលីសហ៊ុន-សែន មានឱកាសដើម្បី គិតគួរពន្យល់ បញ្ចុះបញ្ចូលអ្នកទាំង២ឲ្យដូរគំនិតឡើងវិញ ។ កាលណាសួរអំពីចំណុចនេះឡើងវិញ (សំនួរទី១២ និង ទី១៣ ក្នុងសំបុត្រលោក Jesse Helms), FBI នៅតែឆ្លើយដែលមិនគួរឲ្យជឿបាន ។ FBI បែរជានិយាយថា ការ ដែលបានធ្វើសម្ភាសន៍ជាថ្មីឡើងវិញនោះ គឺធ្វើឡើងនៅក្នុងផ្ទះ លោក ឱម-យិនទៀង, ទីប្រឹក្សា ហ៊ុន-សែន ហើយជាជនជាប់ចោទ ដែលអ្នកទាំង២នោះបានឆ្លើយបដិសេធ ហើយថែមទាំងបានដាក់កំហុសទៅលើលោក សម-រង្ស៊ី ទៅវិញ ។ មួយវិញទៀត, FBI បាននិយាយថា គេបានដឹងបានឮអំពីរបាយការណ៍ដែលថា ឆាយ-វី និង ជុំ-ប៊ុនធឿន បានជាប់ឃុំឃាំងនោះដែរ, ក៏ប៉ុន្តែគិតថា ដូចជាមិនទាក់ទងគ្នា ។ កាលណាបុគ្គលិកគណកម្មការសភា ផ្នែកទំនាក់ទំនងបរទេស សួរដេញដោលតទៅទៀតក្នុងរឿងនេះក្នុងខែកុម្ភៈ ១៩៩៩, FBI មិនបានទទួលស្គាល់ថា របាយការណ៍របស់ខ្លួននោះ មានការខ្វះខាតលើគុណវិបត្តិអ្វីឡើយ ហើយបែជានិយាយថា "ទ្រឹស្តីទាំងអស់មានគុណ សម្បត្តិដូចៗគ្នា" ក្នុងកិច្ចការពារ ។

នេះគឺជាការមួយគួរឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំងដែល FBI បានបំភ្លេចចោលនូវរឿងដែលថា មនុស្សជាប់សង្ស័យទាំង២នាក់ បានជាប់ឃុំឃាំងដោយប៉ូលីសហ៊ុន-សែន, បណ្តាលឲ្យកិច្ចការសម្ភាសន៍ប្រព្រឹត្តិទៅ នៅក្រោមវត្តមានរបស់ទីប្រឹក្សា ហ៊ុន-សែន ហើយបានភ្លេចរឿងដ៏សំខាន់នៅក្នុងរបាយការណ៍របស់ខ្លួន ។ សំណារភាពរបស់មនុស្សទាំង២នាក់ កាលពី ខែមិថុនានោះ ជួនកាលក៏អាចមិនប្រាកដប្រជាដែរ ប៉ុន្តែគួរឲ្យជឿជាងពាក្យដែលគេបានបដិសេធនៅក្នុងខែវិច្ឆិកា ហើយ ដែលបានធ្វើឲ្យខូចប្រយោជន៍ផងដែរ ។ គឺជាការពុំគួរឲ្យជឿសោះឡើយ ដែលថា FBI, ក្រសួងដ៏ធំលេខមួយក្នុង ពិភពលោកក្នុងការអនុវត្តិច្បាប់, ពុំមានសមត្ថភាពនោះ ។ តើ FBI អាចជឿដែរ ដែលថាការដែលប៉ូលីសហ៊ុន-សែន ចាប់ ឆាយ-វី និង ជុំ-ប៊ុនធឿន ឃុំឃាំងមិនមានទំនាក់ទំនងនឹងរឿងបោកគ្រាប់បែក? តើ FBI អាចនឹងមិន ដឹងមិនស្គាល់ថាតើ នរណាជា ឱម-យិនទៀង? ដោយយោលទៅតាមអ្នកសាក៏មាន ដែលមានការពិសោធន៍ដ៏យូរ អង្វែងមកហើយ នៅស្រុកខ្មែរនោះ, គេថា ឱម-យិនទៀង នេះជាមនុស្សដែលគេស្គាល់ថាជា ឧក្រិដ្ឋជនម្នាក់របស់ ហ៊ុន-សែន ។ លោក Staffdel Berkowitz និងលោក Doran បានជួបនឹង ឱម-យិនទៀង នៅថ្ងៃទី៥ ខែកក្កដា ១៩៩៩ ដើម្បីពិភាក្សាអំពីបញ្ហាបោកគ្រាប់បែក ដែលនៅពេលនោះ ឱម-យិនទៀង បានឆ្លើយឥតសមហេតុផលទៅនឹង សំណួររបស់គណៈប្រតិភូ ។ ឱម-យិនទៀង បានប្រាប់ប្រតិភូថា គាត់នឹងធ្វើអង្កេតខ្លួនគាត់ផ្ទាល់ អំពីរឿងបោកគ្រាប់ បែក ហើយនឹងចេញជារបាយការណ៍ នៅពេលឆាប់ៗខាងមុខនេះ ។ នៅពេលដែលគណប្រតិភូសួរថា តើគាត់អង្កេត របៀបណានោះ គាត់បានឆ្លើយតបវិញថា ដើម្បីឲ្យបានលទ្ធផលដ៏ល្អជាក់លាក់នោះ, គាត់ត្រូវការ ការចូលរួមពី សំណាក់លោក សម-រង្ស៊ី ។ ចំពោះអ្នកដែលបានតាមដានរឿងនេះ, នេះមិនមែនជាសេចក្តីថ្លែងការគួរឲ្យជឿនោះ

ឡើយ ។ គេទាំងអស់គ្នាបានដឹងហើយថា គ្មាននរណាម្នាក់ដែលអាចខំប្រឹងប្រែងយ៉ាងខ្លាំងជាងលោក សម-រង្ស៊ី នោះឡើយ ។ ឱម-យិនទៀង បាននិយាយទៀតថា មនុស្សជាប់សង្ស័យឈ្មោះ ប្រេស៊ីល (Brazil) នោះ មានជីវិតរស់នៅឡើយ ហើយរដ្ឋាភិបាលខ្មែរមិនដឹងវានៅឯណាទេ ។

ដូចបានអធិប្បាយខាងលើស្រាប់, FBI ឥតមានពត៌មានអ្វីអំពី Brazil នោះឡើយ ហើយមនុស្សឯទៀតៗដែលសាកសួរពី Brazil ជឿថាវាស្លាប់បាត់ទៅហើយ ។ កាលណាជជីកសួរដេញដោលចុះឡើងអំពីរឿងថា តើមនុស្សឈោះ Brazil នៅទីណា, ជាប់ឃុំឃាំង ឬមួយនៅក្រោមការត្រួតពិនិត្យឃ្លាំមើល, ឱម-យិនទៀង បែរធ្វើអាកប្បកិរិយាចង់គេចឈប់ឆ្លើយ ។ កាលណាសួរថា តើគាត់បំរុងនឹងធ្វើសម្ភាសន៍ មុនពេលគាត់ធ្វើរបាយការណ៍អំពីបោកគ្រាប់បែកនោះ, ឱម-យិនទៀង ឆ្លើយថា ជនឈ្មោះ Brazil ប្រសិនបើនៅរស់ គឺជាកូនសោនៃការស៊ើបអង្កេតនេះទាំងស្រុង ។ រឿងទាំងអស់នេះ ដែលមានការតឹងតែង ហើយដែលគួរឲ្យជឿបាន ព្រមទាំងរឿងដែល FBI បានជួបនឹងមនុស្សម្នាក់ដែលពិបាកនឹងជឿទុកចិត្ត ដូចជា ឱម-យិនទៀង នេះ បានជំរុញឲ្យមានសំណួរកាន់តែច្រើនឡើង ដើម្បីរកឲ្យឃើញអាថ៌កំបាំង និងទីជំរៅក្នុងរឿងនេះ ។

## ម្តងថានៅបន្ត, ម្តងថាឈប់ ហើយភាគច្រើនគឺឈប់

មានឧទាហរណ៍ជាច្រើនផ្សេងទៀត ដែលបានបង្ហាញថា FBI មានការខ្វះខាតក្នុងការស៊ើបអង្កេតរបស់ខ្លួន ។ ឧបមាដូចជាមកទល់នឹងខែវិច្ឆិកា ១៩៩៨, របាយការណ៍បានត្រូវចេញ, សភាមានជំនឿថា ការស៊ើបអង្កេតនោះកំពុងប្រព្រឹត្តទៅនៅឡើយ ។ ប្រយោគចុងក្រោយនៃរបាយការណ៍នោះនិយាយថា “ការស៊ើបអង្កេតបានចប់សព្វគ្រប់អស់ហើយ ។ FBI បានបង្ហាញអំពីលទ្ធផលស៊ើបអង្កេតរបស់គេ ទៅក្រសួងយុត្តិធម៌ ដើម្បីសុំយោបល់កាត់ទោស” (គួររំលឹកថា នៅក្នុងសេចក្តីថ្លែងការខែកុម្ភៈ ១៩៩៩ មន្ត្រីផ្លូវការ FBI ជាច្រើនបានបញ្ជាក់ថា គេមិនអាចនិយាយស្មានអំពីឈ្មោះឧក្រិដ្ឋជននោះឡើយ ។)

រួចនៅថ្ងៃ២៥ ខែមិថុនា ១៩៩៩ គឺបន្ទាប់ពីលោក Jesse Helms បានផ្ញើសារទូលេខទៅ FBI, គណកម្មកាព្រឹទ្ធសភាទំនាក់ទំនងការបរទេស បានទទួលដំណឹងតាមទូរស័ព្ទថា ការស៊ើបអង្កេតនៅកំពុងប្រព្រឹត្តិធ្វើនៅឡើយ ហើយភ្នាក់ងារ FBI នឹងវិលត្រឡប់ទៅស្រុកខ្មែរវិញ ដើម្បីរៀបចំស្រាវជ្រាវរកការពិត ដោយប្រើឧបករណ៍វាស់ជីពចរ ឬវាស់ការដកដង្ហើមចេញចូល របស់ជនជាប់សង្ស័យ ។ នៅពេលដែលខ្ញុំកំពុងសរសេររបាយការណ៍នេះ, គណកម្មការមិនបានទទួលដំណឹងអ្វីពី FBI ថា តើការប្រើម៉ាស៊ីនវាស់ជីពចរនិងដកដង្ហើមចេញចូលនោះ បានប្រព្រឹត្តិធ្វើហើយឬនៅ, ថ្វីត្បិតតែ FBI បាននិយាយថានឹងផ្តល់ពត៌មានមកគណកម្មការ នៅពេលណាបានដំណឹងថ្មីទៀត ។ លោកអគ្គរដ្ឋទូតឈ្មោះ ឃ្វិន (Quinn) បានប្រាប់លោក Staffdel Berkowitz និងលោក Doran នៅថ្ងៃ៥ ខែកក្កដា ថា FBI បានស្ថិតនៅក្នុងប្រទេសកម្ពុជាក្នុងខែឧសភា ១៩៩៩ ដើម្បីធ្វើសម្ភាសន៍ច្រើនទៀត, ធ្វើសម្ភាសន៍ឡើងវិញ ហើយនឹងធ្វើសម្ភាសន៍ដោយប្រើម៉ាស៊ីនជីពចរ-ដកដង្ហើមចេញចូល (Polygraphs) ។ ការស៊ើបអង្កេតនេះ ហាក់ដូចជាធ្វើឡើងសាជាថ្មីទៅវិញទៅមក អាស្រ័យទៅលើថា តើនៅពេលណា ហើយនរណាដែលបានចោទជាសំណួរ ។ ការពិតគឺថា លទ្ធផលបានមកតិចតួចណាស់នៅសំនើបអង្កេតនេះ ចាប់តាំងពីដូវក្តៅឆ្នាំ១៩៩៧ មក ។ មូលហេតុនេះមកពីលោកអគ្គរដ្ឋទូត ឃ្វិន បានឲ្យដំណឹងទៅភ្នាក់ងា FBI ថា ពួកគេជាគោលដៅនៃការវាយប្រហារ ហើយពុំអាចការពារខ្លួន

បានឡើយ ហើយបានធ្វើឲ្យភ្នាក់ងារទាំងអស់នោះ ប្រញាប់ប្រញាល់ចេញពីប្រទេសកម្ពុជានៅខែមិថុនា ១៩៩៧ ។ ក៏ប៉ុន្តែការនិយាយដោះសារនោះ គឺមានកើតឡើងមកត្រឹមតែថ្ងៃនោះទេ ។ មានប្រជាជនខ្មែរជាច្រើន ដែលបានរត់ភៀសខ្លួនមកនៅប្រទេសថៃនៅក្នុងឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៨ ។ ប្រជាជនជាច្រើនរួមបញ្ចូលទាំងឧត្តមសេនិយ ញឹក-ប៊ុនឆៃ ដែល FBI គួរតែធ្វើសម្ភាសន៍នៅទីនោះ ។ ហើយនៅដើមឆ្នាំ១៩៩៨ ស្ថានការណ៍ប្រទេសកម្ពុជាក៏បានស្ងប់ស្ងាត់ហើយដែរ ។ គឺមានតែភ្នាក់ងារ FBI ម្នាក់គត់បានធ្វើសម្ភាសន៍នៅកម្ពុជា (នៅក្នុងមជ្ឈមណ្ឌលហ៊ុន-សែន) ក្នុងរយៈពេលជាងពីរឆ្នាំ គឺចាប់ពីខែមិថុនា ១៩៩៧ មកទល់នឹងខែឧសភា ១៩៩៩ ។ នៅទីបញ្ចប់ មនុស្សដែលត្រូវធ្វើសម្ភាសន៍ជាច្រើននាក់ទៀត ត្រូវបានបដិសេធ ដោយយកលេសថា ជីវិតរបស់ភ្នាក់ងារ FBI ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ។ គេបានធ្វើសម្ភាសន៍ជនជាតិអាមេរិកាំងម្នាក់ ដែលបានរស់នៅក្នុងប្រទេសកម្ពុជាជាយូរឆ្នាំមកហើយ ហើយបាននិយាយថា គាត់និងក្រុមគាត់ បានត្រូវខ្មែរក្រហមគំរាមគំហែងជាច្រើនលើក ច្រើនគ្រា, ក៏ប៉ុន្តែគេយល់យ៉ាងច្បាស់ណាស់ថាការគំរាមគំហែងទាំងនោះ ភាគច្រើនគឺគ្រាន់តែជាការរអ្លួតក្អេងក្អាងតែប៉ុណ្ណោះ ។ សំណួរនិងចម្ងល់លើសពីទំហំនៃសំនើបអង្កេតនេះ នៅតែមានដដែល ។ សួរថា ហេតុអ្វីបានជា FBI ឈប់ស៊ើបអង្កេត នៅពាក់កណ្តាលការងារ ក្នុងរដូវក្តៅ១៩៩៧?

## ក្រសួងការពារប្រទេស : បដិសេធព្រោះរឿងនយោបាយ

មន្ត្រីផ្លូវការក្នុងក្រសួងការពារជាតិនៅ វ៉ាស៊ិនតោន ហើយនិងនៅភ្នំពេញច្រើនតែធ្វើមិនដឹង មិនឮ អំពីអង្កេតការណ៍បោកគ្រាប់បែក ហើយយករឿងនេះប្រគល់ទៅឲ្យ FBI វិញ ។ ឧទាហរណ៍ដូចជានៅក្នុង សវនាការ (Hearing) មួយនៅថ្ងៃទី២៤ ១៩៩៩ នៅចំពោះមុខគណកម្មការព្រឹទ្ធសភា ផ្នែកទំនាក់ទំនងបរទេស រដ្ឋមន្ត្រីលេខាធិការឈ្មោះអលប្រាយ (Albright) បានឆ្លើយថា សំណួរទាំងអស់នេះ គួរសួរទៅ FBI វិញ ។ នៅពេលដែលលោក ស្តាហ្វដែល (Staffdel) និងលោក ដូរ៉ាន់ (Doran) សួរនៅខែធ្នូ ១៩៩៨ សុំឲ្យប្រាប់អំពីមនុស្សនៅពីក្រោយការបោកគ្រាប់បែក លោកប្រធានបេសកកម្មនៅស្ថានទូតភ្នំពេញមិនអាចឆ្លើយបានឡើយ, បែរជានិយាយថា នៅស្រុកខ្មែរមានគ្រាប់បែកជាច្រើនបានផ្ទុះឡើងរៀងរាល់ថ្ងៃ ។ បាទ! ជាការពិតហើយដែលថា មានគ្រាប់បែកជាច្រើនបានផ្ទុះឡើងនៅស្រុកខ្មែរនោះ ក៏ប៉ុន្តែ មន្ត្រីផ្លូវការនៃក្រសួងការពារប្រទេសអាមេរិក ពុំមាននាទីអ្វីបន្តិចបន្តួចសោះ នៅក្នុងរឿងអង្កេតការណ៍នេះ ។ បើតាមរបាយការណ៍របស់ FBI, លោកអគ្គរដ្ឋទូតឈ្មោះ ឃ្វិន (Quinn) បានដឹងពីការសម្ភាសន៍នេះចំនួន៥៦លើក ធ្វើឡើងដោយ FBI នៅពេលដែល FBI បានស្ថិតនៅក្រុងភ្នំពេញ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំជាច្រើនទៀតផង ។ សំណាវភាពរបស់ ឆាយ-វី និង ជុំ-ប៊ុនធឿន ក្នុងខែមិនា ១៩៩៨ នោះ បានប្រព្រឹត្តទៅនៅក្នុងស្ថានទូតអាមេរិកាំងនៅបាងកកប្រទេសថៃ ។ នៅក្នុងសេចក្តីសម្ភាសន៍សាជាថ្មីវិញក្នុងខែវិច្ឆិកា បានប្រព្រឹត្តទៅដោយបុគ្គលិកច្បាប់ (Legal Attache) ប្រចាំក្រុងបាងកក ហើយដោយមន្ត្រីភ្នាក់ងារសន្តិសុខ មកពីស្ថានទូតយើងនៅភ្នំពេញ ។ ការិយាល័យនៅ វ៉ាស៊ីនតោន (Washington) សំរាប់កិច្ចការស្រុកខ្មែរ ក៏បានដឹងបានឮ អំពីរបាយការណ៍សម្ងាត់ដំបូងរបស់ FBI ដែរ ។ សូមបញ្ជាក់ម្តងទៀតថា គេបានដឹងអំពីលទ្ធផល ដែល FBI បានរកឃើញនោះនៅក្នុងខែមិនា ១៩៩៧ ។ ភស្តុតាងមិនអាចប្រកែកបាននោះ បានចុះនៅក្នុងភាគ III នៃរបាយការណ៍នេះ ហើយក្រសួងការពារជាតីក៏បានដឹងបានឮនៅពេលនោះដែរ ។ នៅរយៈពេល២ឆ្នាំនៃអន្តរាគមន៍នេះ ក្រសួងការពារជាតិនៅតែបន្តទំនាក់ទំនងជាមួយ ហ៊ុន-សែន ដដែល

។ បើតាមពត៌មានមួយ ចេញពីប្រភពអ្នកចេះដឹងច្បាស់លាស់អំពីស្រុកខ្មែរ គឺថា ក្រសួងការពារជាតិសហរដ្ឋអាមេរិក មិនចង់ជំរុញរឿងបោកគ្រាប់បែកនេះ ឲ្យវែងឆ្ងាយទៅទៀតទេ គឺគេមិនចង់ឲ្យប្រទេសខ្មែរមានអស្ថេរភាព ព្រោះថាការបង្រួបបង្រួមជាតិទើបតែនឹងចាប់ផ្តើម ហើយងាយបាក់បែកណាស់នៅពេលនេះ ។ គឺពិតណាស់ហើយ គឺ ហ៊ុន-សែន នេះហើយ ដែលមានអំណាចធ្វើឲ្យប្រទេសខ្មែរ មានអស្ថេរភាពដោយបានធ្វើរដ្ឋប្រហារបង្ហូរឈាម ក្នុងថ្ងៃទី៥ ខែកក្កដា ។ ភស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់លើសលប់នេះ បង្ហាញឲ្យឃើញថា ហ៊ុន-សែន និងកងការពារបាននៅពីក្រោយការបោកគ្រាប់បែកនេះ ។ សកម្មភាពស្របច្បាប់មួយបានធ្វើឡើង ដោយដកអគ្គរដ្ឋទូតយើងចេញពីភ្នំពេញមកវិញ ហើយបន្ថយទំនាក់ទំនងជាមួយភ្នំពេញ រហូតដល់ ហ៊ុន-សែន ចុះចេញនិងដកចេញពីដំណែង ។ ផ្ទុយទៅវិញ ក្រសួងការពារជាតិ បានយល់ព្រមគម្រោងផែនការរបស់ជប៉ុន, អនុញ្ញាតឲ្យ ហ៊ុន-សែន រៀបចំបោះឆ្នោតនៅខែកក្កដា ១៩៩៨, បានដាក់អគ្គរដ្ឋទូតថ្មីប្រចាំប្រទេសកម្ពុជាមុនពេលបោះឆ្នោត ហើយនឹងមិនជួយគាំទ្រទាំងអស់ដល់ រណរិទ្ធិ និងលោក សម-រង្ស៊ី ក្នុងសទរដូវ ១៩៩៨ នៅពេលដែលពួកនេះទាមទារថា ហ៊ុន-សែន បន្លំសន្លឹកឆ្នោត ។

## សេចក្តីសន្និដ្ឋាន :

របាយការណ៏នេះចង់បង្ហាញការពិតតែប៉ុណ្ណោះ ។ ការពិតទាំងនោះ មានរាប់បញ្ចូលការពិតដែលមិនអាចប្រកែកបាន ហើយនៅក្នុងករណីយខ្លះ, ការចោទប្រកាន់នោះ យ៉ាងហោចណាស់ក៏មានភស្តុតាងបញ្ជាក់ផងដែរ ។ ការពិតទាំងអស់នេះ បាននាំឲ្យយើងសន្និដ្ឋានដែលមិនអាចគេចផុត ជាបីសណ្ឋាន :

១) កងកម្លាំងអង្គរក្សហ៊ុន-សែន បានចូលរួមរៀបចំផែនការ និងអនុវត្តការគុបគ្រាប់បែក នៅថ្ងៃទី៣០ ខែមិនា ១៩៩៧នេះ ។

២) ហ៊ុន-សែន គឺជាមនុស្សតែមួយគត់ ក្នុងចំណោមមនុស្សពីរនាក់ ដែលមានអំណាច និងឥទ្ធិពលទៅលើកងកម្លាំងអង្គរក្ស ហើយដែលបានដឹង បានឮ និងអនុញ្ញាតឲ្យបោកគ្រាប់បែកនោះ ។

៣) នៅក្នុងខែមិថុនា ១៩៩៧ រដ្ឋាភិបាលសហរដ្ឋអាមេរិក មានភស្តុតាងយ៉ាងសន្ធឹកសន្ធាប់អំពីសេចក្តីសន្និដ្ឋានទី១ និងទី២ខាងលើនេះ ហើយឥតមានបានធ្វើអ្វីទាំងអស់អំពីរឿងនេះ ។

សព្វថ្ងៃនេះ ហ៊ុន-សែន នៅតែកាន់អំណាចនៅស្រុកខ្មែរដដែល ។ ដោយមានការសម្រុះសម្រួលពីរដ្ឋាភិបាលសហរដ្ឋអាមេរិកាំងផង ហ៊ុន-សែន បានទទួលជោគជ័យ ដោយរំលំលទ្ធផលបោះឆ្នោត ដែលអង្គការសហប្រជាជាតិបានរៀបចំឡើង ហើយថែមទាំង មានការគាំទ្រយ៉ាងពេញទំហឹង ពីអន្តរជាតិផង ។ ការដែលរដ្ឋាភិបាលបានស្រុះស្រួលជាមួយ ហ៊ុន-សែន នេះ គឺជាភាគមួយនៃការមិនយកចិត្តទុកដាក់ របស់សហរដ្ឋអាមេរិក ដើម្បីប្រឈមមុខជាមួយ ហ៊ុន-សែន ដែលបានចូលប្រឡូកក្នុងរឿង កាប់សម្លាប់ បង្ហូរឈាមយ៉ាងវង្វាលក៏ដោយ ។